**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ**
លេខាធិការដ្ឋានរដ្ឋបាលសរុប

**របាយការណ៍សង្ខេប**
**ការិយាល័យ ស្រាវជ្រាវព័ត៌មាន និងត្រួតពិនិត្យ**
ពីថ្ងៃទី ០៥-០៩ មីនា ឆ្នាំ២០១៨

## I.អំពីកម្លាំង

-កម្លាំងសរុប ០៨នាក់ (ស្រី ០២នាក់) អវត្តមាន ០នាក់។

## II.សកម្មភាព និង លទ្ធផល

-ចងក្រងរូបភាពខ្លឹមសារសកម្មភាព គ.ជ.ប.ជ និងតាមបណ្តាខេត្តបានចំនួន ០៧សកម្មភាព និងអាប់ឡូតឯកសារចំនួន ០៥ច្បាប់ ចូលក្នុងប្រព័ន្ធ Wiki

-ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៨៖ ឱហ្យាញសៀវភៅ Diary ថ្មីរបស់ គ.ជ.ប.ជ, ស្កេនឯកសារកំណត់ហេតុកិច្ចប្រជុំ គ.ជ.ប.ជ និងអាប់ឡូតទុកក្នុងប្រព័ន្ធ Wiki

-ថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៨៖ កែសម្រួលរៀបចំឯកសារក្នុងប្រព័ន្ធ Wiki ត្រង់ចំណុច MOU, ចងក្រងសកម្មភាព គ.ជ.ប.ជ និងតាមបណ្តាខេត្តពីប្រព័ន្ធទំនាក់ទំនងតេលេក្រាម និងអាប់ឡូតសកម្មភាពចូលក្នុងប្រព័ន្ធ Wiki

-ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨៖ កែសម្រួលលើទម្រង់បច្ចេកទេសលើ Website, ចងក្រងរូបភាពសកម្មភាព-ខ្លឹមសាររបស់ គ.ជ.ប.ជ និងតាមបណ្តាខេត្តពីបណ្តាញ ទំនាក់ទំនង Telegram និងអាប់ឡូតសកម្មភាពទាំងនោះចូលក្នុង Wiki

-ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០១៨៖ ចូលរួមក្នុងពិធី អបអរសាទរខួបលើកទី ១០៧ ទិវាសិទ្ធិនារី ០៨ មីនា ២០១៨ តាមការចាត់បញ្ជូនអគ្គលេខាដ្ឋាន គ.ជ.ប.ជ របស់ក្រសួងកិច្ចការនារី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន នៅសាលមហោស្រពកោះពេជ្រ។

-ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៨៖ ចូលរួមតាមការចាត់សមាសភាពរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចូលរួមក្នុងកម្មវិធីសំណេះសំណាល អបអរសាទរទិវាសិទ្ធនារី ០៨ មីនា ខួបលើកទី ១០៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងលោកជំទាវ នៅទីស្តីការក្រសួងមហាផ្ទៃ និងពេលរសៀលបានជួប សំណេះសំណាលជាមួយលោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅបន្ទប់ប្រជុំរបស់ គ.ជ.ប.ជ។

-ថែទាំប្រព័ន្ធអ៊ិនធើណែត និងម៉ាស៊ីន Sever និងអនុវត្តការងារជាក់ស្តែងមួយចំនួន ដែលថ្នាក់ដឹកនាំដាក់បញ្ជាមក។

## III.ទិសដៅអនុវត្តបន្ត

-ស្កេននិងអាប់ឡូតកំណត់ហេតុកិច្ចប្រជុំថ្នាក់ជាតិ និងអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចូលក្នុងប្រព័ន្ធ Wiki

-បន្តសហការ ធ្វើការប្រមែប្រមូលព័ត៌មានពីគ្រប់មជ្ឈដ្ឋានយក មករក្សាទុកក្នុងប្រព័ន្ធ wiki

-គ្រប់គ្រងតាមដានត្រួតពិនិត្យ កែលម្អកម្មវិធី ប្រព័ន្ធទិន្នន័យព័ត៌មានវិទ្យា គេហទំព័ររបស់គណៈកម្មាធិការជាតិ គ.ជ.ប.ជ និងកម្មវិធីព័ត៌មានវិទ្យា សម្រាប់ការងារផ្សព្វផ្សាយ

-បន្តការងារគ្រប់គ្រងឯកសារ កាលប្បវត្តិ ការងារបណ្ណាល័យ ការងារបណ្ណសារ ចងក្រងទិន្នន័យ ដោយប្រព័ន្ធ អ៊ិនធើណែត

-បន្តរៀបចំប្រព័ន្ធទិន្នន័យរបាយការណ៍ថ្នាក់ជាតិ និងបន្តអភិវឌ្ឍន៍ Website។

ថ្ងៃពុធ ១៣កើត ខែផល្គុន ឆ្នាំរកា ព.ស២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨
**នាយការិយាល័យ**

**វរសេនីយ៍ទោ អ៊ឹង ហាក់លៀង**